01563126

E460/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខៈ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 02 / 2018
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចំពោះមុខ៖ ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យ៉ា សុខន**
ចៅក្រម Claudia FENZ
ចៅក្រម **យូ វុត្ថា**

កាលបរិច្ឆេទ៖ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨
ភាសាដើម៖ ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# សេចក្ដីសម្រេចលើកទីប្រាំមួយ ស្ដីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. ប្រវត្តិនីតិវិធី

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង តាមការផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញពីររូបគឺ វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លើនណា ("អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃជនជាប់ចោទ និងធ្វើរបាយការណ៍ស្តីពីសម្បទាបច្ចុប្បន្នរបស់គាត់ក្នុងការចូលរួមសវនាការ។[1] បន្ទាប់ពីបានពិនិត្យវាយតម្លៃជនជាប់ចោទទៅតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះរួចមក អ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួននៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៨។ នៅថ្ងៃដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណៅនៃរបាយការណ៍ទាំងនេះ[2] ជូនទៅភាគី ដោយអញ្ជើញភាគីឱ្យដាក់នៅត្រឹមថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៨ នូវសំណើសុំសួរដេញដោលអ្នកជំនាញនៅក្នុងសវនាការលើរបាយការណ៍ និងមតិយោបល់របស់ពួកគេអំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ [3] ។ ដោយសារថាមិនទទួលបានសំណើណាមួយទេនោះ ទើបមិនមានសវនាការលើបញ្ហានេះឡើយ។

២. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចចំនួនប្រាំដងដោយឡែកពីគ្នាថា នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[4]។ សម្រាប់គោលបំណងនៃសេចក្តីសម្រេចនេះ អង្គជំនុំជម្រះ

---

[1] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាកំណត់តាមកាលបរិច្ឆេទនៃការវាយតម្លៃ ឯកសារ E460 ("ដីកាបង្គាប់") ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧។

[2] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ នួន ជា ឯកសារ E460/2 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ ខៀវ សំផន ឯកសារ E460/3 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨ ("របាយការណ៍ស្តីពី ខៀវ សំផន")។ របាយការណ៍ទាំងពីរត្រូវបានចាត់ថ្នាក់ជារបាយការណ៍សម្ងាត់បំផុត។ របាយការណ៍ទាំងនេះបានដាក់ចូលក្នុងសំណុំរឿងជាផ្លូវការនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ពីព្រោះថា ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ គឺជាថ្ងៃឈប់សម្រាប់ផ្លូវការរបស់ អ.វ.ត.ក.។

[3] អ៊ីម៉ែលពីអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគី ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៨។

[4] សេចក្តីសម្រេចលើកទីប្រាំស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ហាស្មារតីប្រចាំត្រីមាស ("ដីកាបង្គាប់") ឯកសារ E389/5 ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦ ("សេចក្តីសម្រេចលើកទីប្រាំស្តីពីសម្បទា")។ សេចក្តីសម្រេចលើកទីបួនទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E329/7 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើកទីបួនស្តីពីសម្បទា")។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងកាចូលរួមសវនាការ ឯកសារ E301/11 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើកទីពីរលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើសម្បទា

សាលាដំបូងបានបង្គាប់ឱ្យអ្នកជំនាញ រាយការណ៍ព័ត៌មាន ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចបានគូសបញ្ជាក់នៅក្នុងសាលដីកា *Strugar* ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថាតើបច្ចុប្បន្ននេះ ជនជាប់ចោទម្នាក់ៗមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបានដែរ ឬ យ៉ាងណា ក្នុងគោលបំណងសម្រាប់ចេញសាលក្រម [5]។

## ២. ការពិនិត្យវាយតម្លៃរបស់អ្នកជំនាញ

៣. អ្នកជំនាញបានពិនិត្យវាយតម្លៃលើ នួន ជា នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ និងបានពិនិត្យលើរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់គ្រូពេទ្យប្រចាំការនៅមន្ទីរឃុំឃាំង អ.វ.ត.ក. និងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅទីក្រុងភ្នំពេញ [6]។ នៅក្នុងរបាយការណ៍ស្តីពី នួន ជា អ្នកជំនាញបញ្ជាក់ថា នួន ជា ធ្លាប់មានជំងឺរុំារ៉ៃមួយចំនួន ប៉ុន្តែ កត់សម្គាល់ថា សម្ពាធឈាម ចង្វាក់បេះដូង សភាពស្បែកស្លាំង ការដកដង្ហើម ចលនាសាច់ដុំ និងការស្តាប់ឮរបស់គាត់ មានសភាពធម្មតាទាំងអស់[7]។

៤. នួន ជា បានត្អូញត្អែរពីការឈឺចង្កេះចាប់តាំងពីឆ្នាំ ២០០៧ មកម្លេះ[8]។ អ្នកជំនាញរាយការណ៍ថា វេជ្ជបណ្ឌិតដែលព្យាបាលគាត់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានកត់សម្គាល់ថា អាការៈឈឺចង្កេះរបស់គាត់នៅដដែលមិនប្រែប្រួលឡើយ ដោយអាការៈនេះធូរស្បើយវិញនៅពេលគាត់នៅស្ងៀម ហើយគាត់អាចក្រោកអង្គុយបានរយៈពេលខ្លី[9]។ វេជ្ជបណ្ឌិតដែលព្យាបាលគាត់បានបន្ថែមថា ទោះបីជាការធ្វើចលនារបស់គាត់យឺតជាងមុនក៏ដោយ ក៏គាត់នៅតែអាចដើរដោយខ្លួនឯងបាន

---

របស់ នួន ជា ក្នុងកាចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[5] ដីកាបង្គាប់ កថាខណ្ឌ ៦ ដកស្រង់ពី រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Strugar* អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY, IT-01-42-T សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៦ និងរឿងក្តីរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Strugar* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY, IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("រឿងក្តី *Strugar*") កថាខណ្ឌ ៥៥។

[6] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៣, ៥, ៧, ២៦។

[7] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦, ១៩។

[8] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦។ *សូមមើល* សេចក្តីសម្រេចលើកទីប្រាំស្តីពីសម្បទា កថាខណ្ឌ ៤។

[9] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ កថាខណ្ឌ ៧។

ដោយប្រើដែកច្រត់ និងមានការជួយទប់ខ្លះ [10] ។ អ្នកជំនាញយល់ថា ការឈឺខ្នងរបស់គាត់គឺដោយសារឆ្អឹងចង្កេះគាត់ចុះខ្សោយរ៉ាំរ៉ៃ ដែលបណ្តាលមកពីវ័យជរា និងរបួសចាស់របស់គាត់ ប៉ុន្តែបញ្ជាក់ថា បញ្ហានេះមិនគួរប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការឡើយ[11]។

៥. នួន ជា ក៏បានត្អូញត្អែរផងដែរពីអាការៈវិលមុខនាពេលកន្លងមកនេះ ដោយអាការៈនេះបន្តកើតឡើងម្តងម្កាលនៅពេលដែលគាត់កម្រើកខ្លួន[12]។ អ្នកជំនាញយល់ថា អាការៈវិលមុខរបស់ នួន ជា គឺបណ្តាលមកពីការចុះខ្សោយសរសៃប្រសាទនៅក្នុងត្រចៀក ដោយសារភាពចាស់ជរារបស់គាត់ ប៉ុន្តែអ្នកជំនាញបានបញ្ជាក់ថា បញ្ហានេះមិនគួរប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការឡើយ[13]។ អ្នកជំនាញសន្និដ្ឋានថា នួន ជា មានសុខភាពល្អ បើធៀបទៅនឹងអាយុរបស់គាត់ និងស្ថានភាពសុខភាពរ៉ាំរ៉ៃរបស់គាត់[14]។

៦. នៅក្នុងអំឡុងពេលអ្នកជំនាញសម្ភាសគាត់ នួន ជា អាចក្រោកអង្គុយបានដោយមិនបាច់មានអ្វីទប់រហូតដល់ទៅ ៦០ នាទី[15]។ នួន ជា និយាយឮៗ និងច្បាស់ៗ និងចាំបានថា គាត់ធ្លាប់បានជួបជាមួយអ្នកជំនាញកាលពីពេលមុន ទោះបីជាគាត់មិនចាំឈ្មោះក៏ដោយ[16]។ នួន ជា បានប្រាប់អ្នកជំនាញថា គាត់ជឿថា ភ្នែករបស់គាត់មើលមិនឃើញច្បាស់ទេ ដូចនេះហើយគាត់ស្តាប់វិទ្យុវិញ[17]។

៧. អ្នកជំនាញរាយការណ៍ថា វេជ្ជបណ្ឌិតបីនាក់ក្នុងចំណោមវេជ្ជបណ្ឌិតដែលព្យាបាល នួន ជា នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានកត់សម្គាល់ថា ការចងចាំរបស់គាត់មិនមានបញ្ហាទេ ហើយជាពិសេស បានកត់សម្គាល់អំពី "ការចងចាំបានល្អ" របស់គាត់ ពាក់ព័ន្ធនឹងប្រវត្តិសុខភាពរបស់គាត់ នាពេលថ្មីៗកន្លងទៅនេះ[18]។ វេជ្ជបណ្ឌិតព្យាបាលក៏បានកត់សម្គាល់ផងដែរថា អារម្មណ៍របស់

---

10 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៧។

11 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៣, ៤៧។

12 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៨, ២៤។ *សូមមើល* សេចក្តីសម្រេចលើកទីប្រាំស្តីពីសម្បទា កថាខណ្ឌ ៥។

13 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៤, ៤៧។

14 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤៧។

15 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៦, ៤៨។

16 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៧។

17 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៨។

18 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៧។

01563130



គាត់មិនខុសប្រក្រតីត្រង់ណាទេ[19]។ អ្នកជំនាញយល់ឃើញថា នួន ជា អាចផ្ដង់អារម្មណ៍បានពេញលេញនៅក្នុងអំឡុងពេលនៃការសម្ភាសន៍រយៈពេល ៦០ នាទី និងកត់សម្គាល់ថា គាត់ហាក់ដូចជាមិនមានភាពនឿយហត់ ឬ មិនស្រួលក្នុងចិត្តឡើយ។ គាត់នៅតែមានស្មារតីរហ័សរហួន និងបានឆ្លើយតបយ៉ាងច្បាស់លាស់ចំពោះសំណួរដែលបានសួរទៅគាត់[20]។ អ្នកជំនាញក៏បានរាយការណ៍ផងដែរថា នួន ជា ដឹងអំពីបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់[21]។ លើសពីនេះទៀត នួន ជា ទទួលបានពិន្ទុដែលចាត់ទុកថា ធម្មតា ចំពោះការពិនិត្យស្ថានភាពផ្លូវចិត្តដោយអ្នកជំនាញ ដែលជាការធ្វើតេស្តដែលគេប្រើជាទូទៅដើម្បីពិនិត្យមើលការចុះខ្សោយផ្នែកសតិបញ្ញា[22]។ អ្នកជំនាញកត់សម្គាល់ថា ការធ្វើតេស្តផ្នែកបញ្ញាស្មារតីជាទៀតទាត់ ក្រោមទម្រង់ជាការធ្វើតេស្តសង្ខេបផ្នែកបញ្ញាស្មារតី (AMT) ត្រូវបានធ្វើឡើងចំពោះ នួន ជា រៀងរាល់បីខែម្ដង[23]។ មានតែការធ្វើតេស្តនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ ម្ដងប៉ុណ្ណោះ ដែលពិន្ទុគាត់បង្ហាញថា មុខងារបញ្ញាស្មារតីរបស់គាត់បានចុះខ្សោយបន្តិច[24]។ នៅក្នុងការធ្វើតេស្តចំនួនបីលើកបន្តបន្ទាប់ទៀត គឺនៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៧ និងថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៧ គាត់ទទួលបានពិន្ទុដែលចាត់ទុកថាធម្មតាវិញ[25]។ ជារួម អ្នកជំនាញយល់ឃើញថា សភាពផ្លូវចិត្តរបស់គាត់មានលក្ខណៈធម្មតា ហើយការចងចាំរយៈពេលខ្លី ការផ្ចង់អារម្មណ៍ និងការយកចិត្តទុកដាក់របស់គាត់នៅល្អប្រសើរទាំងអស់ សម្រាប់មនុស្សមានវ័យដូចគាត់[26]។ ជាពិសេស អ្នកជំនាញយល់ឃើញថា នួន ជា មិនមានបញ្ហាផ្លូវចិត្ត ឬ បញ្ហាផ្លូវកាយ ដែលប៉ះពាល់លទ្ធភាពរបស់គាត់ ក្នុងការប្រើសមត្ថភាពចាំបាច់ ដែលបានកំណត់នៅក្នុងរឿងក្ដី *Strugar* នោះឡើយ[27]។

---

[19] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ២៧។

[20] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ២៩។

[21] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ៣០, ៣៨។

[22] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ៣១។

[23] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ២៦។

[24] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ២៦។

[25] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ២៦។

[26] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ៣២-៣៣។

[27] របាយការណ៍ស្ដីពី នួន ជា កថាខណ្ឌ ៣៤-៤៥, ៥២។

៨. អ្នកជំនាញកត់សម្គាល់ថា នួន ជា មានអាយុ ៩១ ឆ្នាំ មានសភាពទ្រុឌទ្រោម ហើយ ប្រឈមនឹង "ការចុះខ្សោយខ្លាំងផ្នែកមុខងារផ្សេងៗនៃរាងកាយ"[28]។ អ្នកជំនាញផ្តល់អនុសាសន៍ថា ឱ្យគាត់បន្តទទួលការព្យាបាលដោយចលនា យ៉ាងហោចណាស់ឱ្យបានម្តង ឬ ពីរដងក្នុងមួយសប្តាហ៍[29]។ អ្នកជំនាញក៏យល់ឃើញផងដែរថា ការចងចាំ និងមុខងារបញ្ញាស្មារតីរបស់ នួន ជា អាច មានការធ្លាក់ចុះជាបណ្តើរៗបន្ថែមទៀត ទៅតាមអាយុរបស់គាត់[30]។ ដូច្នេះ អ្នកជំនាញណែនាំឱ្យធ្វើការពិនិត្យមុខងារបញ្ញាស្មារតីរបស់គាត់ឱ្យបានទៀងទាត់ ជាពិសេស ប្រសិនបើឃើញថាមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ [31] ។ អ្នកជំនាញ លើកឡើងថាដើម្បីធានាថា នួន ជា អាចចូលរួមសវនាការប្រកបដោយប្រសិទ្ធភាពបំផុតនោះ នួន ជា អាចអង្គុយលើកៅអីមានកង់ ឬ កៅអីមានដៃ និងមានបង្អែកខ្ពស់ទៅក្រោយដើម្បីជួយទប់គាត់ នៅក្នុងអំឡុងពេលសវនាការ[32]។

## ៣. ច្បាប់ជាធរមាន

៩. ដើម្បីកំណត់ថា មានសម្បទាក្នុងការចូលរួមសវនាការ ជនជាប់ចោទត្រូវមានលទ្ធភាពចូលរួមសវនាការប្រកបដោយអត្ថន័យ ដែលអាចឱ្យគាត់អនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុងកម្រិតមួយដែលគាត់អាចចូលរួមបានដោយមានប្រសិទ្ធភាពនៅក្នុងការជំនុំជម្រះក្តីលើរូបគាត់ និងយល់ដឹងពីផ្នែកសំខាន់ៗនៃកិច្ចដំណើរការនីតិវិធី[33]។

## ៤. សំអាងហេតុ

១០. នៅក្នុងការវាយតម្លៃនេះ អង្គជំនុំជម្រះពិចារណាទៅលើកត្តាទាំងអស់ដែលពាក់ព័ន្ធ រួមមានភស្តុតាងពីអ្នកជំនាញ ការសង្កេតរបស់អង្គជំនុំជម្រះផ្ទាល់ ផលប៉ះពាល់ដោយសារស្ថានភាពសុខភាពរបស់ជនជាប់ចោទ លទ្ធភាពមានវិធានការជាក់ស្តែងដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារការចុះខ្សោយសុខភាព ហើយថាជនជាប់ចោទត្រូវបានតំណាង និងផ្តល់ការប្រឹក្សាយោបល់ពីក្រុមមេធាវីដែលមានសមត្ថភាព។

---

28 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២២។

29 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២២។

30 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៥៣។

31 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៥៣។

32 របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤៨។

33 រឿងក្តី*Strugar* កថាខណ្ឌ ៥៥។

១១. បន្ទាប់ពីបានពិនិត្យលើរបាយការណ៍ស្តីពី នួន ជា រួចមក អង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា នួន ជា នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយបច្ចុប្បន្នេះ ពុំមានការចុះខ្សោយផ្នែកស្មារតី ឬ រាងកាយ ដែលរារាំងគាត់មិនឱ្យបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ នោះទេ។

១២. អង្គជំនុំជម្រះកត់សម្គាល់លើអនុសាសន៍របស់អ្នកជំនាញ ដែលណែនាំឱ្យធ្វើការពិនិត្យមុខងារបញ្ញាស្មារតីរបស់ នួន ជា ឱ្យបានទៀតទាត់ ហើយរំឮកថា នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានបង្គាប់ឱ្យបន្តធ្វើតេស្តបញ្ញាស្មារតីរបស់គាត់ ប្រចាំត្រីមាសរហូតដល់ខែ មិថុនា ឆ្នាំ ២០១៨ គឺត្រូវធ្វើឡើងដោយក្រុមគ្រូពេទ្យវិជ្ជាជីវៈដែលមានកិច្ចសន្យាផ្តល់សេវាជូនអង្គភាពមន្ទីរឃុំឃាំង អ.វ.ត.ក. ("អង្គភាពសេវាសុខភាព")[34]។

**យោងតាមសំអាងហេតុ ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**បញ្ជាក់** ថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

យោងតាមដីកាបង្គាប់ឱ្យធ្វើតេស្តលើបញ្ញាស្មារតីប្រចាំត្រីមាស **បង្គាប់÷**

១. ត្រូវបន្តធ្វើតេស្តមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា យ៉ាងហោចណាស់ម្តងជារៀងរាល់ត្រីមាស។

២. អ្នកជំនាញដែលបានតែងតាំង ត្រូវរៀបចំតេស្តដើម្បីវាយតម្លៃមុខងារបញ្ញាស្មារតីរបស់ នួន ជា និងធ្វើការជាមួយនឹងបុគ្គលិក ដែលមានគុណវុឌ្ឍិនៅអង្គភាពសេវាសុខភាពរបស់ អ.វ.ត.ក. ដើម្បីធ្វើតេស្តទាំងនេះ និងធ្វើរបាយការណ៍អំពីលទ្ធផលជូនអង្គជំនុំជម្រះសាលាដំបូង។

---

34 ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីរបស់ជនជាប់ចោទប្រចាំត្រីមាស និងកំណត់ពេលវេលានៃការធ្វើតេស្ត ឯកសារ E389/5/2 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧ ("ដីកាបង្គាប់ឱ្យធ្វើតេស្តលើបញ្ញាស្មារទីប្រចាំត្រីមាស") កថាខណ្ឌ ៣-៥។

01563133



**បង្គាប់** ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ យោងតាមដីកាបង្គាប់ឲ្យធ្វើតេស្តលើបញ្ហាស្មារតីប្រចាំត្រីមាស សម្របសម្រួល និងកំណត់ពេលវេលានៃការធ្វើតេស្តដែលនៅសេសសល់ទាំងអស់ ដោយធ្វើតេស្តបន្ទាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៨។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**